**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: 00៤/0៧-0៩-២00៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: អោ អាន

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៦

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 18-July-2016, 08:00
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណារបស់ អោ អាន ស្តីពីបញ្ហាថា តើការវាយប្រហារដោយរដ្ឋ ឬអង្គការមួយទៅលើ សមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន អាចត្រូវបានចាត់ទុកថាជា ឧក្រិដ្ឋកម្មប្រឆាំងនឹង មនុស្សជាតិដែរឬយ៉ាងណា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់១៩៧៩**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី**

មុំ លុជ្ស

Richard ROGERS
Göran SLUITER

**<u>ផ្ញើជូន៖</u>**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**សហមេធាវីការពារក្តី យឹម ទិត្យ៖**

សូ មូស្សេន្នី

Suzana TOMANOVIĆ

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

## I. **សេចក្តីផ្តើម**

1. លោក អោ អាន តាមរយៈសហមេធាវីរបស់គាត់ (បន្ទាប់ពីនេះហៅកាត់ថា "មេធាវីការពារក្តី") សូមដាក់សារណានេះ *តាមសេចក្តីអំពាវនាវរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសុំឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង០០៤ និងអ្នកដែលមិនមែនជាភាគី* ("*សំណើសុំឲ្យដាក់សារណា*")[1] ទាក់ទងបញ្ហាថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការមួយទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន អាច ឬក៏មិនអាចជាការវាយប្រហារ ដែលសំដៅលើប្រជាជនស៊ីវិល ("*លក្ខខណ្ឌតម្រូវសម្រាប់ប្រជាជនស៊ីវិល*") បើយោងតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[2]។

2. មេធាវីការពារក្តីសូមលើកឡើងថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការមួយទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន មិនអាចចាត់ទុកថាជាការវាយប្រហារសំដៅលើប្រជាជនស៊ីវិលឡើយ ដោយសារមូលហេតុដូចតទៅ៖ (ក) មិនមានភស្តុតាងពីការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់* (*opinio juris*) ដែលរួមបញ្ចូលយុទ្ធជនទៅក្នុងវិសាលភាពនៃ"ជនស៊ីវិល"ឡើយ ផ្ទុយទៅវិញ អត្ថន័យទូទៅនៃឃ្លានេះ និងការអនុវត្តដែលមានស្រាប់របស់រដ្ឋ បង្ហាញពីការមិនរាប់បញ្ចូលយុទ្ធជនទេ។ (ខ) ការប្រើប្រាស់ការបកស្រាយពាក្យ "ជនស៊ីវិល" ឲ្យហួសពីអត្ថន័យទូទៅ រំលោភបំពានទៅលើគោលការណ៍នីត្យានុកូលភាព និង (គ) ប្រសិនបើមិនមានភស្តុតាងដែលបង្ហាញពីការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់* ទាក់ទងនឹងបញ្ហានេះទេ នោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវដោះស្រាយភាពមិនច្បាស់លាស់នេះ ដោយផ្តល់ជាប្រយោជន៍ដល់ អោ អាន និងជនត្រូវចោទដទៃទៀត អនុលោមតាមគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)*។

---

[1] សំណុំរឿង០០៤/០៧-០៩-២០០៩, *"សេចក្តីអំពាវនាវរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សុំឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង០០៤ និងអ្នកដែលមិនមែនជាភាគី"*, ឯកសារ D306, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦, កថាខណ្ឌ ៣, ៦, ១១។

[2] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, រួមជាមួយច្បាប់វិសោធនកម្ម ដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) ("*ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក*"), មាត្រា ៥ ('ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមិនមានអាជ្ញា យុកាល គឺជាអំពើទាំងឡាយណាដែលប្រព្រឹត្តិឡើង ជាផ្នែកនៃការវាយប្រហារជាប្រព័ន្ធ និងទ្រង់ទ្រាយធំ សំដៅលើប្រជាជន ស៊ីវិល ដោយផ្អែកលើមូលដ្ឋានជាតិសាសន៍ នយោបាយ ជាតិពិន្ទុ ពូជសាសន៍ ឬសាសនា ….")។

II. **ច្បាប់ជាធរមាន**

**ក. ការកំណត់ទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ**

3. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវកំណត់ដោយអត្ថិភាពនៃការអនុវត្តរបស់រដ្ឋជាទូទៅ និងមានភាពស៊ីសង្វាក់គ្នានឹងទស្សនៈច្បាប់ (ឧទាហរណ៍ ការទទួលយក ឬ ការទទួលស្គាល់ដោយរដ្ឋថា ការអនុវត្តមួយជាការចាំបាច់)[3]។ ប្រហែលគ្នានេះដែរ អង្គបុរេជំនុំជម្រះបានសម្រេចថា "អំពើដែលពាក់ព័ន្ធមិនត្រូវបានរាប់ថាត្រឹមតែជាទម្លាប់អនុវត្តអចិន្ត្រៃយ៍ប៉ុណ្ណោះទេ ប៉ុន្តែអំពើទាំងនោះត្រូវតែជាទម្លាប់អនុវត្តអចិន្ត្រៃយ៍ ឬត្រូវបានយកមកអនុវត្តក្នុងលក្ខណៈអាចជាភស្តុតាងឲ្យគេជំនឿថា ទម្លាប់អនុវត្តនេះជាកាតព្វកិច្ច តាមរយៈអត្ថិភាពនៃវិធាននៃច្បាប់ដែលតម្រូវឲ្យមានទម្លាប់អនុវត្តនេះ"[4]។ តុលាការអាចពឹងផ្អែកទៅលើច្បាប់សន្ធិសញ្ញា ឬយុត្តិសាស្ត្រអន្តរជាតិ ដើម្បីកំណត់ថាតើ *ទស្សនៈច្បាប់* គាំទ្រដល់អត្ថិភាពរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរឬទេ[5]។

**ខ. វិធានស្តីពីការបកស្រាយ**

4. មាត្រា ៣១ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ឆ្នាំ១៩៦៩ (*"អនុសញ្ញាទីក្រុងវីយែន"*) ចែងថា៖

1) សន្ធិសញ្ញាត្រូវបកស្រាយចេតនាសុចរិត ដោយអនុលោមតាមអត្ថន័យទូទៅ ដែលត្រូវផ្តល់ដល់ពាក្យពេចន៍នៃសន្ធិសញ្ញា នៅក្នុងបរិបទរបស់វា ហើយផ្អែកតាមគោលដៅ និងគោលបំណងរបស់សន្ធិសញ្ញា។

2) បរិបទសម្រាប់គោលបំណងនៃការបកស្រាយសន្ធិសញ្ញា ក្រៅពីអត្ថបទដែលរួមទាំងបុព្វកថា និងឧបសម្ព័ន្ធ ត្រូវរួមមាន៖

---

[3] សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អជតក, *"សាលដីកា ("សាលដីកាសំណុំរឿង ០០១")"*, ឯកសារ F28, ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២, កថាខណ្ឌ ៩២, ភ្ជាប់ជាឧបសម្ព័ន្ធ ១។

[4] សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ38), *"សាលដីកាលើបណ្តឹងសាទុក្ខ ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសហឧក្រិដ្ឋកម្មរួម ('សាលដីកាលើសហឧក្រិដ្ឋកម្មរួម')"*, ឯកសារ D97/15/9, ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០, កថាខណ្ឌ ៥៣, ភ្ជាប់ជាឧបសម្ព័ន្ធ ២ (ដកស្រង់ *North Sea Continental shelf* (រឿងក្តី *សហភាពសាធារណរដ្ឋអាល្លឺម៉ង់ តទល់នឹង ប្រទេសដាណឺម៉ាក, សហភាពសាធារណរដ្ឋអាល្លឺម៉ង់ តទល់នឹង ប្រទេសហូឡង់)*, តុលាការយុត្តិធម៌អន្តរជាតិ, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៦៩, កថាខណ្ឌ ៧៧)។

[5] *"សាលដីកាលើសហឧក្រិដ្ឋកម្មរួម"*, កថាខណ្ឌ ៥៣, ៦០។ *"សាលដីកាសំណុំរឿង ០០១"*, កថាខណ្ឌ ៩៣។

i. កិច្ចព្រមព្រៀងនានាទាក់ទងជាមួយសន្ធិសញ្ញា ហើយត្រូវបានធ្វើឡើងដោយភាគីទាំងអស់ ដែលទាក់ទងជាមួយនឹងការសម្រេចលើសន្ធិសញ្ញា

ii. លិខិតុបករណ៍នានាដែលធ្វើឡើងដោយភាគីមួយ ឬច្រើន ទាក់ទងជាមួយការសម្រេចលើ សន្ធិសញ្ញា ហើយភាគីដទៃទៀតទទួលយក ធ្វើជាលិខិតុបករណ៍ ទាក់ទងនឹងសន្ធិសញ្ញា

3) គួរត្រូវបានពិចារណា រួមជាមួយនឹងបរិបទ៖

i. កិច្ចព្រមព្រៀងនាពេលបន្ទាប់ទាំងឡាយណាដែលត្រូវបានធ្វើឡើងរវាងភាគីនានាទាក់ទង នឹងការបកស្រាយសន្ធិសញ្ញា ឬការអនុវត្តប្បញ្ញត្តិរបស់សន្ធិសញ្ញានោះ

ii. ការអនុវត្តនាពេលបន្ទាប់ទាំងឡាយ ក្នុងការអនុវត្តសន្ធិសញ្ញា ដែលបង្កើតនូវកិច្ចព្រម ព្រៀងរវាងភាគី ទាក់ទងនឹងការបកស្រាយ

iii. វិធានពាក់ព័ន្ធទាំងឡាយនៃច្បាប់អន្តរជាតិដែលអាចអនុវត្តន៍បានទាក់ទងនឹងភាគីនានា[6]

5. តុលាការអន្តរជាតិបានបញ្ជាក់ឡើងវិញពីវិធានស្តីពីការបកស្រាយសន្ធិសញ្ញាដែលមានចែងនៅក្នុង អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩[7]។ តុលាការយុត្តិធម៌អន្តរជាតិ (*ICJ*) បានសម្រេចថា "សន្ធិ សញ្ញាចាំបាច់ត្រូវបកស្រាយដោយចេតនាសុចរិត យោងតាមអត្ថន័យទូទៅនៃពាក្យពេចន៍ ទៅតាម បរិបទរបស់សន្ធិសញ្ញា ព្រមទាំងស្របតាមគោលដៅ និងគោលបំណង។ ដោយសារតែវិធានការ

---

[6] អនុសញ្ញាទីក្រុងវីយែន, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩, មាត្រា ៣១, ភ្ជាប់ជាឧបសម្ព័ន្ធ ៣។

[7] *ជម្លោះទឹកដី (Lybian Arab Jamahiriya/Chad)*, "សាលក្រម (*'សាលក្រមស្តីពីជម្លោះទឹកដី របស់តុលាការយុត្តិធម៌អន្តរជាតិ'*)", តុលាការយុត្តិធម៌អន្តរជាតិ, របាយការណ៍ឆ្នាំ ១៩៩៤, កថាខណ្ឌ ៤១, ភ្ជាប់ជាឧបសម្ព័ន្ធ ៤។ សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ជ, *"សាលក្រមលើសំណុំរឿង ០០២/០១"*, ឯកសារ E313, ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤, កថាខណ្ឌ ១៨៥ ដល់១៨៦, ភ្ជាប់ជាឧបសម្ព័ន្ធ ៥ (បកស្រាយពាក្យ "ជនស៊ីវិល" ផ្អែកលើអត្ថន័យទូទៅ)។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Martic, ICTY, IT-95-11-A, *សាលដីកា*, ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨, កថាខណ្ឌ ២៩៧, ភ្ជាប់ជាឧបសម្ព័ន្ធ ៦ (សម្រេចថាប្បញ្ញត្តិចាំបាច់ត្រូវបកស្រាយ អនុលោមតាម "អត្ថន័យធម្មតា និងទូទៅ តាមបរិបទដែលអត្ថន័យនោះបានបង្កើតឡើង"," ដោយពិចារណាទៅលើគោលដៅ និងគោលបំណង)។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tadic និងអ្នកដទៃទៀត*, ICTY, IT-95-9, *"សេចក្តីសម្រេចលើសំណើសុំជំនួយផ្នែកតុលាការ ដែលត្រូវផ្តល់ដោយ SFOR និងអ្នកដទៃទៀត"*, ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០០, កថាខណ្ឌ ៤៧, ភ្ជាប់ជាឧបសម្ព័ន្ធ ៧ (ដកស្រង់គោលការណ៍នៃអត្ថន័យទូទៅ ដែលមានចែងក្នុងអនុសញ្ញាទីក្រុងវីយែន)។ រឿងក្តី*Golder តទល់នឹង ចក្រភពអង់គ្លេស*, ECHR, no. 4451/70, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៥, កថាខណ្ឌ ៣០, ភ្ជាប់ជាឧបសម្ព័ន្ធ ៨ (សម្រេចថាគោលការណ៍បកស្រាយជាសារវ័ន្តគឺថា ពាក្យពេចន៍នៃសន្ធិសញ្ញា គួរត្រូវបកស្រាយអនុលោមតាមបរិបទ និងអត្ថន័យទូទៅរបស់ពួកគេ)។

បន្ថែម ដំណោះស្រាយអាចត្រូវមើលទៅលើការបកស្រាយលើការងារត្រៀមរៀបចំសន្ធិសញ្ញា និងកាលៈទេសៈនៃការបញ្ចប់សន្ធិសញ្ញានោះ"[8]។

**គ. និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

**i. មុនឆ្នាំ១៩៧៥**

6. ត្រឹមឆ្នាំ ១៩៧៥ លិខិតុបករណ៍គតិយុត្តជាច្រើន បានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយមានលក្ខខណ្ឌតម្រូវស្តីពីជនស៊ីវិល[9]។ មាត្រា ៦(គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ[10] បានរួមបញ្ចូលលក្ខខណ្ឌតម្រូវស្តីពីជនស៊ីវិល និងលក្ខខណ្ឌតម្រូវស្តីពីជម្លោះប្រដាប់អាវុធ៖

[8] "*សាលក្រមស្តីពីជម្លោះទឹកដី តុលាការយុត្តិធម៌អន្តរជាតិ*", កថាខណ្ឌ ៤១។

[9] ធម្មនុញ្ញតុលាការយោធាអន្តរជាតិ, ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងស្តីពីការចោទប្រកាន់ និងការផ្តន្ទាទោស ចំពោះឧក្រិដ្ឋជនសង្គ្រាមចម្បងរបស់ក្រុម Axis អឺរ៉ុប, ត្រូវបានអនុម័ត និងចូលជាធរមាននៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥, 82 UNTS 279 ('*ធម្មនុញ្ញរបស់ តុលាការយោធាអន្តរជាតិ*'), មាត្រា ៦(គ) ភ្ជាប់ជាឧបសម្ព័ន្ធ ៩។ ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង, ការផ្តន្ទាទោសលើបុគ្គលដែលមានពិរុទ្ធភាពក្នុងឧក្រិដ្ឋកម្មសង្គ្រាម, ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥, កម្រងឯកសារផ្លូវការចំនួនបីរបស់ក្រុមប្រឹក្សាគ្រប់គ្រងអាល្លឺម៉ង់ ៥០ ដល់៥៥ (ឆ្នាំ១៩៤៦) ("*ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*"), មាត្រា II(១)(គ), ភ្ជាប់ជាឧបសម្ព័ន្ធ ១០។ ធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា, ដីកាបង្គាប់ទូទៅ ១, General Headquarters Supreme Commander of the Allied Forces, ថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៤៦, ដែលត្រូវបានវិសោធនកម្មនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៤៦ ("*ធម្មនុញ្ញទីក្រុងតូក្យូ*"), មាត្រា ៥(គ), ភ្ជាប់ជាឧបសម្ព័ន្ធ ១១។ គោលការណ៍ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ក្នុងធម្មនុញ្ញតុលាការ Nuremberg និងនៅក្នុងសាលក្រមរបស់តុលាការ ដោយមានបទអត្ថាធិប្បាយ,*Yearbook of the International Law Commission* (ឆ្នាំ១៩៥០), Vol. II, 374-378 ('*គោលការណ៍ Nuremberg*"), គោលការណ៍ ៦(គ), ភ្ជាប់ជាឧបសម្ព័ន្ធ ១២។ សេចក្តីព្រាងក្រមស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសុវត្ថិភាពមនុស្សជាតិ *Yearbook of the International Law Commission* (ឆ្នាំ១៩៥១), 133-137 ("*សេចក្តីព្រាងក្រមឆ្នាំ១៩៥១*'), មាត្រា ២(១០), ភ្ជាប់ជាឧបសម្ព័ន្ធ ១៣។ អនុសញ្ញាស្តីពីការមិនអនុវត្តន៍អាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, អនុម័តនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៦៨, សេចក្តីសម្រេចលេខ 2391 (XXIII) របស់មហាសន្និបាត, ចូលជាធរមាននៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧០, 754 UNTS 73 ("*អនុសញ្ញាស្តីពីការមិនអនុវត្តន៍អាជ្ញាយុកាល*"), ភ្ជាប់ជាឧបសម្ព័ន្ធ ១៤។

[10] សំណុំរឿង00៣/07-09-2009-អ.វ.ត.ក-ក.ស.ច.ស, "*សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំឱ្យបញ្ជាក់បំភ្លឺទាក់ទង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ* ('*សេចក្តីសម្រេចលើទំនាក់ទំនងជម្លោះប្រដាប់អាវុធ*')", ឯកសារ D87/2/1.7/1, ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦, កថាខណ្ឌ ២៤ (បញ្ជាក់ថាមាត្រា ៦(គ) គឺជា "ដំណាក់កាលដំបូងនៃទស្សនៈស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវផ្លាស់ប្តូរទៅជាច្បាប់វិជ្ជមាន")។ Beth Van Schaack, "*និយម*

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន មនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌នានា ដែលបានធ្វើឡើងប្រឆាំងជនស៊ីវិល ទាំងនៅមុន ឬនៅក្នុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញ ដោយផ្អែកលើមូលដ្ឋាននយោបាយ ពូជសាសន៍ ឬសាសនា ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬទាក់ទងជាមួយឧក្រិដ្ឋកម្មណាមួយ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ ទោះបីជារំលោភបំពាន ឬមិនរំលោភបំពាន ទៅលើច្បាប់ជាតិរបស់ប្រទេសដែលត្រូវបានប្រព្រឹត្តក៏ដោយ[11]។

7. តាមធម្មនុញ្ញតុលាការយោធាអន្តរជាតិ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានបែងចែកជាពីរប្រភេទគឺ៖ ប្រភេទសម្លាប់ និងប្រភេទធ្វើទុក្ខបុកម្នេញ[12]។ អ្នកស្រាវជ្រាវបានលើកទឡ្ហីករណ៍ថាធម្មនុញ្ញតុលាការយោធាអន្តរជាតិ អនុវត្តលក្ខខណ្ឌតម្រូវស្តីពីជនស៊ីវិល ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រភេទសម្លាប់ ប៉ុន្តែមិនអនុវត្តចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រភេទធ្វើទុក្ខបុកម្នេញទេ[13]។ ប៉ុន្តែការអះអាងនេះត្រូវបានរិះគន់ថា "មិននាំទៅដល់លទ្ធផលគួរជាទីពេញចិត្តឡើយ"[14]។

---

*ន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ ការដោះស្រាយភាពមិនសមស្របគ្នា"*, 37 Colum. J. Transnat'l L. 787, 1998-1999, ទំព័រ ៧៨៩, ភ្ជាប់ជាឧបសម្ព័ន្ធ ១៥។

[11] "ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ", មាត្រា ៦(គ) (ដោយគូសបញ្ជាក់បន្ថែម)។

[12] *សូមមើល* Antonio Cassese, "*ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* ", (3d ed., Oxford: 2013), ទំព័រ ១០១, ភ្ជាប់ជាឧបសម្ព័ន្ធ ១៦។ Van Schaak, ទំព័រ ៨០២។

[13] Cassese, ទំព័រ ១០២។ Egon Schwelb, "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ",*The British Yearbook of Intl Law* (ឆ្នាំ១៩៤៦), 23rd Year of Issue, Geoffrey Cumberlege, Oxford Univ. Press, 178-226, ទំព័រ ១៩០, ភ្ជាប់ជាឧបសម្ព័ន្ធ ១៧។

[14] រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Tadic*, ICTY, IT-94-1-T, "សាលក្រម", ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៧, កថាខណ្ឌ ៦៤០, ភ្ជាប់ជាឧបសម្ព័ន្ធ ១៨ (ដកស្រង់គណៈកម្មការស្តីពីឧក្រិដ្ឋកម្មសង្គ្រាម របស់អង្គការសហប្រជាជាតិ, *ប្រវត្តិនៃគណៈកម្មការស្តីពីឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ និងការអភិវឌ្ឍន៍ច្បាប់សង្គ្រាម ៣២ ដល់៣៨* (គណៈកម្មការស្តីពីឧក្រិដ្ឋកម្មសង្គ្រាម របស់អង្គការសហប្រជាជាតិ៖ ទីក្រុងឡុងដ៍, ឆ្នាំ១៩៤៨), ទំព័រ ១៩៣)។ Schwelb, ទំព័រ ១៩០ ដល់១៩១ ("ការបកស្រាយបានបង្ហាញនូវភាពខុសគ្នារវាងឧក្រិដ្ឋកម្មប្រភេទមនុស្សឃាត និងប្រភេទធ្វើទុក្ខបុកម្នេញ ដែលពាក់ព័ន្ធចំពោះឃ្លាពិសេសមួយនេះ មិននាំទៅដល់លទ្ធផលគួរជាទីពេញចិត្ត សម្រាប់លទ្ធផលដូចតទៅ៖ ឧក្រិដ្ឋកម្មប្រភេទមនុស្សឃាតដែលពាក្យ "ប្រជាជនស៊ីវិល" ពិតជាសំដៅទៅលើ បទល្មើសធ្ងន់ធ្ងរជាង "ការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលដ្ឋាននយោបាយ ពូជសាសន៍ ឬសាសនា", ប្រសិនបើយើងរឹតបន្តឹងឧក្រិដ្ឋកម្មប្រភេទធ្វើទុក្ខបុកម្នេញ ឱ្យសំដៅតែទៅលើការធ្វើទុក្ខបុកម្នេញ ដែលមិនឈានដល់អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ និងការនិរទេស។ ពិតជាពិបាកក្នុងការយល់ដឹងអំពីសនិទានកម្មនៃបទបញ្ញត្តិ ដែលតាមបទ

8. ប្រហែលគ្នានឹងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិដែរ និយមន័យនៅក្នុងច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ បានរក្សាលក្ខខណ្ឌតម្រូវស្តីពីជនស៊ីវិល។ ប៉ុន្តែនិយមន័យនេះមិនបានលើកឡើងពីលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងជម្លោះប្រដាប់អាវុធឡើយ៖

> ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ អំពើសាហាវយង់ឃ្នង់ និងបទល្មើស រួមបញ្ចូលដោយមិនកម្រិតត្រឹមមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភបំពាន និងអំពើអមនុស្សធម៌ដទៃទៀត ដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនស៊ីវិល ឬការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលដ្ឋាននយោបាយ ពូជសាសន៍ ឬសាសនា ទោះបីជារំលោភបំពាន ឬមិនរំលោភបំពានទៅលើច្បាប់ជាតិ នៃប្រទេសដែលត្រូវបានប្រព្រឹត្តក៏ដោយ[15]។

9. ធម្មនុញ្ញទីក្រុងតូក្យូបានឆ្លុះបញ្ចាំងពីនិយមន័យនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ ដោយរួមបញ្ចូលទាំងលក្ខខណ្ឌតម្រូវស្តីពីប្រជាជនស៊ីវិល និងលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងជម្លោះប្រដាប់អាវុធ៖

> ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមាន អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ដទៃទៀត (ដែលប្រព្រឹត្តឡើងប្រឆាំងប្រជាជនស៊ីវិល នៅមុនពេល) ឬក្នុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលដ្ឋាននយោបាយ ឬពូជសាសន៍ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬទាក់ទងជាមួយឧក្រិដ្ឋកម្មណាមួយ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ ទោះបីជារំលោភបំពាន ឬមិនរំលោភបំពានទៅលើច្បាប់ជាតិ របស់ប្រទេសដែលត្រូវបានប្រព្រឹត្តក៏ដោយ[16]។

10. គោលការណ៍ Nuremberg ដែលបង្កើតឡើងដោយគណៈកម្មការច្បាប់អន្តរជាតិ តាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ 177(II)[17] បានថ្លែងឡើងជាថ្មីម្តងទៀតនូវពាក្យពេចន៍នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ ទាក់ទងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖

---

ប្បញ្ញត្តិនេះ ចំនួនមនុស្សដែលទទួលបានការការពារពីឧក្រិដ្ឋកម្មដែលស្រាលជាង (ការធ្វើទុក្ខបុកម្នេញ) និងធំជាងការការពារដែលជនរងគ្រោះសក្តានុពលទទួលបាន ប្រឆាំងបទល្មើសធ្ងន់ធ្ងរជាង ប្រភេទមនុស្សឃាត")។

[15] ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង, មាត្រា II ១(គ) (ដោយគូសបញ្ជាក់បន្ថែម)។ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ "គោលបំណងនៃច្បាប់នេះ គឺដើម្បីកំណត់នូវមូលដ្ឋានច្បាប់ដូចគ្នានៅក្នុងប្រទេសអាល្លឺម៉ង់ សម្រាប់ការជំនុំជម្រះបុគ្គលនានា ដែលមិនត្រូវជំនុំជម្រះដោយតុលាការយោធាអន្តរជាតិ", *សេចក្តីសម្រេចលើទំនាក់ទំនងជម្លោះប្រដាប់អាវុធ*, កថាខណ្ឌ ២៦។

[16] ធម្មនុញ្ញតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ("*ធម្មនុញ្ញទីក្រុងតូក្យូ*"), មាត្រា ៥(គ) (ដោយគូសបញ្ជាក់បន្ថែម)។

[17] សេចក្តីសម្រេចលេខ 177 (II)របស់មហាសន្និបាត, ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៤៧, កថាខណ្ឌ (ក), ភ្ជាប់ជាឧបសម្ព័ន្ធ ១៩។

អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ដទៃទៀត *(ដែលបានធ្វើឡើងចំពោះប្រជាជនស៊ីវិល)* ឬការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលដ្ឋាននយោបាយ ពូជសាសន៍ ឬសាសនា នៅពេលដែលអំពើបែបនេះត្រូវបានប្រព្រឹត្ត ឬការធ្វើទារុណកម្មបែបនេះត្រូវបានប្រព្រឹត្តឡើង នៅពេលអនុវត្តឧក្រិដ្ឋកម្ម ឬទាក់ទងជាមួយឧក្រិដ្ឋកម្ម ប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាម[18]។

11. នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខមនុស្សជាតិ ដែលបានអនុម័តកាលពីឆ្នាំ១៩៥១ *("សេចក្តីព្រាងក្រមឆ្នាំ១៩៥១")* គណៈកម្មការបានតម្រូវថា រាល់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (បើទោះបីជាមិនបានដាក់ឈ្មោះថាបែបនេះក៏ដោយ) ធ្វើឡើងចំពោះប្រជាជនស៊ីវិល ដូច្នេះហើយ បោះបង់ចោលការបែងចែករវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រភេទមនុស្សឃាត និងប្រភេទធ្វើទុក្ខបុកម្នេញ៖

អំពើអមនុស្សធម៌ធ្វើឡើងដោយអាជ្ញាធរនៃរដ្ឋ ឬដោយបុគ្គលឯកជន *ប្រឆាំងនឹងប្រជាជនស៊ីវិល* ដូចជាអំពើមនុស្សឃាត ឬការសម្លាប់រង្គាល ឬការដាក់ឲ្យទៅជាទាសករ ឬការនិរទេស ឬការធ្វើទុក្ខបុកម្នេញដោយមូលដ្ឋាននយោបាយ ពូជសាសន៍ សាសនា ឬវប្បធម៌ នៅពេលដែលអំពើបែបនេះត្រូវបានធ្វើឡើង ក្នុងពេលប្រព្រឹត្តឧក្រិដ្ឋកម្ម ឬទាក់ទងនឹងបទល្មើសណាមួយ ដែលត្រូវបានកំណត់ក្នុងមាត្រានេះ[19]។

12. គួរឲ្យកត់សម្គាល់នោះគឺថា សេចក្តីព្រាងក្រមឆ្នាំ១៩៥១ បានពិចារណាដល់ការសង្កេតរបស់រដ្ឋជាសមាជិកទាំង១៣ ហើយមិនមានរដ្ឋជាសមាជិកណាមួយ ជំទាស់ទៅនឹងលក្ខខណ្ឌតម្រូវស្តីពីជនស៊ីវិលឡើយ[20]។ នៅក្នុងរបាយការណ៍ដែលភ្ជាប់មកជាមួយសេចក្តីព្រាងនោះ គណៈកម្មការមិនបានពិភាក្សាថាតើ យុទ្ធជនអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬអត់នោះទេ ប៉ុន្តែបែរជាផ្តោតទៅលើការបកស្រាយពាក្យ "ជនស៊ីវិល" ដើម្បីរួមបញ្ចូលអំពើដែលប្រព្រឹត្តិឡើងដោយចារីប្រឆាំងនឹងប្រជាជនឯងទៅវិញ[21]។

---

[18] គោលការណ៍ច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ក្នុងធម្មនុញ្ញ តុលាការ Nuremberg និងនៅក្នុងសាលក្រមរបស់តុលាការ ('*គោលការណ៍ Nuremberg*'), គោលការណ៍ ៦(គ) (ដោយគូសបញ្ជាក់បន្ថែម)។.

[19] សេចក្តីព្រាងក្រមឆ្នាំ១៩៥១, មាត្រា ២(១០) (ដោយគូសបញ្ជាក់បន្ថែម)។

[20] មហាសន្និបាត, 'មតិទទួលបានពីរដ្ឋាភិបាលនានាទាក់ទងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសប្រឆាំងសន្តិភាពនិងសុវត្ថិភាពមនុស្សជាតិ និងបញ្ហានៃការកំណត់និយមន័យការឈ្លានពាន", UN Doc. A/2162, ថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៥២, ទំព័រ ២៨, ភ្ជាប់ជាឧបសម្ព័ន្ធ ២០។ UN Doc. A/2162/Add.1, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៥២, ភ្ជាប់ជាឧបសម្ព័ន្ធ ២១។

[21] របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ, UN GAOR, 5th Sess., Supp. No 12, U.N. Doc. A/1316 (ឆ្នាំ១៩៥០), ទំព័រ ៣៧៧, កថាខណ្ឌ ១២៤, ភ្ជាប់ជាឧបសម្ព័ន្ធ ២២។

13. នៅក្នុងឆ្នាំ១៩៥៤ គណៈកម្មការបានអនុម័តយកសេចក្តីព្រាងច្បាប់លើកទីពីរ ("សេចក្តីព្រៀងក្រមឆ្នាំ១៩៥៤") ដែលបានកំណត់ផងដែរនូវនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយមានលក្ខខណ្ឌតម្រូវស្តីពីប្រជាជនស៊ីវិល ហើយមិនបានញែកបំបែកឧក្រិដ្ឋកម្មប្រភេទមនុស្សឃាតចេញពីឧក្រិដ្ឋកម្មប្រភេទធ្វើទុក្ខបុកម្នេញឡើយ[22]។ ចាំបាច់ត្រូវកត់សម្គាល់ថា ទោះបីជាលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងប្រដាប់អាវុធត្រូវបានពិភាក្សាដេញដោលនៅក្នុងគណៈកម្មការក៏ដោយ តែលក្ខខណ្ឌតម្រូវស្តីពីប្រជាជនស៊ីវិលមិនត្រូវបានចាត់ទុកថាជាការជំទាស់ឡើយ[23]។

14. អនុសញ្ញាឆ្នាំ១៩៦៨ស្តីពីការមិនអនុវត្តអាជ្ញាយុកាល បានយកនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ ហើយបានរួមបញ្ចូលជាសំខាន់នូវលក្ខខណ្ឌតម្រូវស្តីពីប្រជាជនស៊ីវិល[24]។ ពាក់ព័ន្ធនឹងអនុសញ្ញានេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ថា "ដោយមិនគិតពីចំនួនហត្ថលេខី ការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក គោលជំហរ

---

[22] សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសុវត្ថិភាពមនុស្សជាតិ, *Yearbook of the International Law Commission*, 1954, Vol. I, កំណត់ត្រាសង្ខេបនៃកិច្ចប្រជុំលើកទី៦ (ថ្ងៃទី៣ ខែមិថុនា - ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥៤) ('*សេចក្តីព្រាងក្រមឆ្នាំ ១៩៥៤*'), ទំព័រ ១៤០ ដល់១៤៨, កថាខណ្ឌ ៣៦, ភ្ជាប់ជាឧបសម្ព័ន្ធ ២៣ ("អំពើអមនុស្សធម៌ដោយរដ្ឋ ឬបុគ្គលឯកជន ដែលធ្វើឡើងក្រោមការជំរុញ ឬអត់អោនដោយអាជ្ញាធរ ប្រឆាំងប្រជាជនស៊ីវិល ដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយផ្អែកលើមូលដ្ឋាននយោបាយ សង្គម ពូជសាសន៍ សាសនា ឬវប្បធម៌")។ ចំពោះឥទ្ធិពលនៃសេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ ទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ជាពិសេសថា "មហាសន្និបាតអង្គការសហប្រជាជាតិគ្រាន់តែសម្រេចផ្អាក ការពិចារណាបន្តទៅលើសេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ ព្រោះខ្លួនកំពុងរង់ចាំការដាក់របាយការណ៍ ស្តីពីនិយមន័យនៃការឈ្លានពាន។ មហាសន្និបាតអង្គការសហប្រជាជាតិមិនបានបដិសេធការអនុម័តសេចក្តីព្រាងច្បាប់ ដោយសារតែការខ្វែងយោបល់គ្នាទៅលើធាតុផ្សំបង្កើតឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ក្នុងន័យនេះឥទ្ធិពលនៃការដែលគ្រាន់តែមិនអនុម័ត បានក្លាយទៅជាមិនសូវពាក់ព័ន្ធ ហើយឥទ្ធិពលជំនួសជាក់ស្តែងនៃទស្សនៈច្បាប់ ត្រូវបានគាំទ្រដោយសេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ រួមទាំង vis-a-vis the equally non-adopted គោលការណ៍ Nuremberg ដែលមិនបានអនុម័តដូចគ្នា ដែលទទួលបានភាពលេចធ្លោកាន់តែខ្លាំង"។ *សេចក្តីសម្រេចលើទំនាក់ទំនងជម្លោះប្រដាប់អាវុធ*, កថាខណ្ឌ ៥៦។

[23] *សូមមើល ឧទាហរណ៍ សេចក្តីព្រាងក្រមឆ្នាំ១៩៥៤*, "កិច្ចប្រជុំលើកទី២៦៩, ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៥៤", ទំព័រ ១៤០ ដល់១៤៦ (បញ្ជាក់ពីការពិភាក្សាក្នុងចំណោមសមាជិកគណៈកម្មការ ដែលបង្ហាញថា លក្ខខណ្ឌតម្រូវប្រជាជនស៊ីវិលត្រូវបានទទួលយកយ៉ាងទូលំទូលាយ ហើយថាសមាជិកជាច្រើនចង់ធ្វើឲ្យមានភាពខុសគ្នារវាងឧក្រិដ្ឋកម្មទាំងអស់នេះធៀបនឹងការរំលោភសិទ្ធិមនុស្ស)។

[24] *អនុសញ្ញាស្តីពីការមិនអនុវត្តន៍អាជ្ញាយុកាល*, មាត្រា I(ខ)។

ដែលបង្ហាញដោយរដ្ឋាភិបាលនៃរដ្ឋជាសមាជិកទាក់ទងនឹងអាជ្ញាយុកាល និងអនុសញ្ញាអាប៉ាថេត ដែលអាចកំណត់ថាជាសកម្មភាពដោយពាក្យសម្តីរបស់រដ្ឋ គឺជាភស្តុតាងនៃការអនុវត្តរបស់រដ្ឋ”[25]។

*ii. ក្រោយឆ្នាំ១៩៧៩*

15. លក្ខខណ្ឌតម្រូវស្តីពីប្រជាជនស៊ីវិលនៅតែបន្តមាននៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បន្ទាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដោយមានករណីលើកលែងតិចតួចប៉ុណ្ណោះ។ ករណីលើកលែងមួយ គឺសេចក្តីព្រាងក្រមឆ្នាំ១៩៩១ ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ ដែលបានប្រើដោយគណៈកម្មការ[26]។ សេចក្តីព្រាងនេះបានងាកចេញខ្លាំងពីក្រមឆ្នាំ១៩៥១ និង១៩៥៤ ហើយងាកចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមាននៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ ជាពិសេសដោយសារតែសេចក្តីព្រាងនេះបានដកចេញនូវលក្ខខណ្ឌតម្រូវស្តីពីជនស៊ីវិល[27]។ ដោយសារតែសេចក្តីព្រាងនេះខុសប្លែកខ្លាំងពីអត្ថបទច្បាប់ពាក់ព័ន្ធកន្លងមកមិនត្រូវបានចាត់ទុកថាជាការបង្ហាញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ ហើយនៅពេលក្រោយមកមិនត្រូវបានគេពិចារណាឡើយ[28]។

16. លក្ខន្តិកៈឆ្នាំ១៩៩៣ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី(“តុលាការ *ICTY*”) និងលក្ខន្តិកៈឆ្នាំ១៩៩៤ ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា (“តុលាការ ICTR”) បានបញ្ចូលលក្ខខណ្ឌតម្រូវស្តីពីប្រជាជនស៊ីវិល[29]។

---

[25] *សេចក្តីសម្រេចលើទំនាក់ទំនងជម្លោះប្រដាប់អាវុធ*, កថាខណ្ឌ ៦២ ដល់៦៣។

[26] Phyllis Hwang, *កំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ*, 22 Fordham Int’l L.J. 457 (ខែធ្នូ ឆ្នាំ១៩៩៨), ទំព័រ ៤៦៥ ដល់៤៦៦, ភ្ជាប់ជាឧបសម្ព័ន្ធ ២៤ (ពិភាក្សាពីសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសុវត្ថិភាពមនុស្សជាតិ, *Yearbook of the International Law Commission* (ឆ្នាំ ១៩៩១), Vol. II (“*សេចក្តីព្រាងក្រមឆ្នាំ ១៩៩១*”))។

[27] Hwang, ទំព័រ ៤៦៥ ដល់៤៦៦។

[28] Hwang, ទំព័រ ៤៦៥ ដល់៤៦៦ (បញ្ជាក់ថា សេចក្តីព្រាងច្បាប់ឆ្នាំ ១៩៩១ ខុសពីសេចក្តីព្រាងច្បាប់ឆ្នាំ ១៩៥៤ ក្នុងលក្ខណៈមួយចំនួន ដូច្នេះហើយ “សារៈសំខាន់របស់សេចក្តីព្រាងច្បាប់នេះក្នុងការឆ្លុះបញ្ចាំងពីការអភិវឌ្ឍន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងច្បាប់អន្តរជាតិគឺមានកម្រិតកំណត់”)។

[29] លក្ខន្តិកៈតុលាការ ICTY, មាត្រា ៥។ លក្ខន្តិកៈតុលាការ ICTR, មាត្រា ៣។

17. លក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ក៏កំណត់ផងដែរថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវរួមបញ្ចូលលក្ខខណ្ឌតម្រូវស្តីពីប្រជាជនស៊ីវិល៖ "សម្រាប់គោលបំណងនៃលក្ខន្តិកៈនេះ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" សំដៅលើអំពើដូចតទៅ ដែលនៅពេលប្រព្រឹត្តជាផ្នែកមួយ នៃការវាយប្រហារជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយមានការដឹងឮអំពីការវាយប្រហារនេះ"[30]។ កថាខណ្ឌទីពីរនៃមាត្រានេះក៏ពន្យល់ផងដែរអំពីពាក្យ "វាយប្រហារ"៖ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" គឺមានន័យថាជាការប្រព្រឹត្តិដែលរួមបញ្ចូល ការប្រព្រឹត្តិអំពើជាច្រើន ដូចមានយោងនៅក្នុងកថាខណ្ឌ ១ សំដៅប្រឆាំងប្រជាជនស៊ីវិល ដោយអនុលោមតាម ឬដោយមានការជំរុញពីគោលនយោបាយរដ្ឋ ឬអង្គការ ឲ្យប្រព្រឹត្តិអំពើបែបនេះ"[31]។

18. ជាចុងក្រោយ នៅក្នុងខែសីហា ឆ្នាំ២០១០ គំនិតផ្តួចផ្តើមស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលរួមបញ្ចូលអ្នកជំនាញច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងអ្នកដទៃទៀត បានធ្វើសេចក្តីព្រាងសំណើអនុសញ្ញាអន្តរជាតិស្តីពីការរារាំង និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលនៅតែរក្សាលក្ខខណ្ឌស្តីពីប្រជាជនស៊ីវិល ដែលដូច្នេះបង្កើតឡើងដោយផ្អែកទៅលើ និងជួយគាំទ្រដល់លក្ខន្តិកៈទីក្រុងរ៉ូម[32]។

## ឃ. គោលការណ៍នីត្យានុកូលភាព

---

[30] លក្ខន្តិកៈទីក្រុងរ៉ូម (អនុម័តនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ហើយចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២) (ដោយគូសបញ្ជាក់បន្ថែម), មាត្រា ៧(១)។

[31] លក្ខន្តិកៈទីក្រុងរ៉ូម, មាត្រា ៧(២)(ក)។

[32] *អនុសញ្ញាអន្តរជាតិដែលបានស្នើឡើងសម្រាប់ការការពារ និងដាក់ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* ("*អនុសញ្ញាដែលបានស្នើឡើង*"), គំនិតផ្តួចផ្តើមស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, Washington University School of Law, Whitney R. Harris World Law Institute, ខែសីហា ឆ្នាំ២០១០, អាចរកបាននៅ http://law.wustl.edu/harris/cah/docs/EnglishTreatyFinal.pdf ('សម្រាប់គោលបំណងនៃអនុសញ្ញាបច្ចុប្បន្ន, "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" សំដៅលើសកម្មភាពដូចតទៅ ដែលពេលប្រព្រឹត្តជាផ្នែកនៃការវាយប្រហារជាប្រព័ន្ធ ឬជាទ្រង់ទ្រាយធំ សំដៅលើប្រជាជនស៊ីវិល ដោយមានការដឹងឮពីការវាយប្រហារ ..."ការវាយប្រហារទៅលើប្រជាជនស៊ីវិល" សំដៅលើការប្រព្រឹត្តិណា ដែលពាក់ព័ន្ធការប្រព្រឹត្តិអំពើច្រើន ដូចមានចែងនៅក្នុងកថាខណ្ឌ ១ ប្រឆាំងប្រជាជនស៊ីវិល ដោយអនុលោមតាម ឬដោយមានការជម្រុញ ពីគោលនយោបាយរដ្ឋ ឬអង្គការ ឲ្យប្រព្រឹត្តិការវាយប្រហារបែបនេះ')។

19. គោលការណ៍នីត្យានុកូលភាព ដែលគេក៏ហៅថា*គោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង* ក៏បានហាមឃាត់ប្រតិសកម្មនៃឧក្រិដ្ឋកម្ម និងបានកំណត់ថា អំពើដែលបានហាមឃាត់ចាំបាច់ត្រូវមានភាពជាក់ច្បាស់គ្រប់គ្រាន់ ដើម្បីជាគោលការណ៍ណែនាំដល់អាកប្បកិរិយារបស់ប្រជាជន[33]។ តាមគោលការណ៍នេះ ច្បាប់ព្រហ្មទណ្ឌចាំបាច់ត្រូវតែវិភាគឲ្យល្អិតល្អន់ ហើយការពង្រីកតាមន័យដូចត្រូវបានហាមឃាត់[34]។ តុលាការអាចបកស្រាយ និងបញ្ជាក់ទៅលើច្បាប់ដែលនៅជាធរមាន ប៉ុន្តែខ្លឹមសារច្បាប់ចាំបាច់ត្រូវតែអាចប្រមើលមើលបាន និងអាចបញ្ជាក់បានដោយជនជាប់ចោទនៅពេលមានអំពើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់[35]។

20. តាមច្បាប់អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវតែគោរពគោលការណ៍នីត្យានុកូលភាព។ អង្គជំនុំជម្រះ "ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនឲ្យសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិ

---

[33] *សាលដីកាសំណុំរឿង 00១*, កថាខណ្ឌ ៩១។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Vasiljevic*, ICTY, IT-98-32-T, *"សាលក្រម"*, ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២00២, កថាខណ្ឌ ១៩៣, ភ្ជាប់ជាឧបសម្ព័ន្ធ ២៥ (សម្រេចថា "ពិតជាមិនអាចទទួលយកបានទេក្នុងការផ្តន្ទាទោសជនជាប់ចោទម្នាក់ ដោយផ្អែកលើមូលដ្ឋាននៃការហាមឃាត់មួយ ដែលពិចារណាដល់ភាពជាក់លាក់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយនឹងអនុញ្ញាតឲ្យមានការបញ្ជាក់បំភ្លឺតាមលំដាប់លំដោយទៅលើវិធាននានារបស់ក្រមព្រហ្មទណ្ឌ ដែលអាចមិនច្បាស់លាស់គ្រប់គ្រាន់ក្នុងការសម្រេចពីអំពើ និងបំបែកឧក្រិដ្ឋជនចេញពីភាពអាចអនុញ្ញាតិបាន ឬមិនអាចដឹងបានគ្រប់គ្រាន់ថាជាបទល្មើស នៅពេលវេលាពាក់ព័ន្ធ")។

[34] Cassese, ទំព័រ ៣៣។

[35] *"សាលដីកាសំណុំរឿង 00១"*, កថាខណ្ឌ ៩៥, ៩៦ (សម្រេចថា គោលការណ៍នីត្យានុកូលភាព រារាំងអង្គជំនុំជម្រះមិនឲ្យ "បង្កើតច្បាប់ថ្មី ឬបកស្រាយច្បាប់ជាធរមាន ឲ្យហួសពីដែនកំណត់សមស្រប នៃការបញ្ជាក់បំភ្លឺដែលអាចទទួលយកបាន")។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Hadsihasanovic និងអ្នកដទៃទៀត*, ICTY, IT-01-47-AR72, *"សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ហំជំទាស់ទៅនឹងយុត្តាធិការ ទាក់ទងការទទួលខុសត្រូវរបស់ថ្នាក់លើ"*, ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២00៣, កថាខណ្ឌ ៣៤, ភ្ជាប់ជាឧបសម្ព័ន្ធ ២៦ (សម្រេចថា ជនជាប់ចោទត្រូវតែអាចប្រមើលមើលដឹងថាជាបទល្មើស និងអាចដឹងថាមានច្បាប់ចែងថាការប្រព្រឹត្តិរបស់គាត់អាចផ្តន្ទាទោសបាន)។ រឿងក្តី *Kafkaris តទល់នឹង Cyprus*, ECHR, no. 21906/04, ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២00៨, កថាខណ្ឌ ១៤0, ភ្ជាប់ជាឧបសម្ព័ន្ធ ២៧ (សម្រេចនិយមន័យនៃបទល្មើស និងពិរុទ្ធភាព ដែលចាំបាច់ត្រូវតែអាចប្រមើលមើលដឹងថាជាបទល្មើស និងអាចដឹងថាមានច្បាប់ចែង)។ រឿងក្តី *SW តទល់នឹង U.K.*, ECHR, no. 20166//92, ថ្ងៃទី២២ *ខែវិច្ឆិកា ឆ្នាំ១៩៩៥, កថាខណ្ឌ ៣៦*, ភ្ជាប់ជាឧបសម្ព័ន្ធ ២៨ (សម្រេចថា ការបកស្រាយរបស់តុលាការត្រូវបានអនុញ្ញាតិ "ប្រសិនបើការអភិវឌ្ឍន៍ដែលជាលទ្ធផល ស៊ីសង្វាក់គ្នាជាមួយធាតុផ្សំនៃបទល្មើស ហើយអាចប្រមើលមើលដឹងដោយសមហេតុផល")។

ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ឆ្នាំ១៩៦៦"[36]។ មាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែង និងកំណត់និយមន័យនៃគោលការណ៍នីត្យានុកូលភាព។

21. លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការគោរពតាមគោលការណ៍នីត្យានុកូលភាព គឺជាបុរេលក្ខខណ្ឌសម្រាប់ការអនុវត្តយុត្តាធិការ[37]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "ដើម្បីជាការធានាបន្ថែម ការព្រួយបារម្ភអំពីភាពយុត្តិធម៌ និងដំណើរការនីតិវិធីឆាប់រហ័ស ដែលជាមូលដ្ឋាននៃគោលការណ៍នីត្យានុកូលភាពអន្តរជាតិតម្រូវថា រាល់បទល្មើសដែលបានចោទប្រកាន់ ឬរាល់ទម្រង់នៃការទទួលខុសត្រូវ "ត្រូវមានលក្ខណៈអាចយល់ដឹងជាមុនបានគ្រប់គ្រាន់ថាជាបទល្មើស ហើយច្បាប់ដែលចែងអំពីការទទួលខុសត្រូវបែបនេះដែលអាចចូលមើលបានដោយជនជាប់ចោទនៅពេលនោះ""[38]។ ភាពអាចដឹងជាមុនថាជាបទល្មើសមានន័យថា ជនជាប់ចោទ "អាចដឹងថាអំពើដែលខ្លួនប្រព្រឹត្ត គឺជាអំពើល្មើសព្រហ្មទណ្ឌក្នុងន័យដែលគេអាចយល់ដឹងជាទូទៅ ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយនោះទេ"[39]។ ភាពអាចដឹងថាមានច្បាប់ចែងមានន័យថា ឧក្រិដ្ឋភាពនៃអំពើនោះគឺ "ជនជាប់ចោទអាចដឹងថាមានច្បាប់ចែងគ្រប់គ្រាន់" តាមរយៈសន្ធិសញ្ញាអន្តរជាតិ ច្បាប់ទំនៀមទម្លាប់ ឬច្បាប់ជាតិ[40]។

---

[36] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៣ ថ្មី។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (*'កិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក'*), មាត្រា ១២។ សូមមើល រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៣១, ៣៨ (តម្រូវឱ្យតុលាការការពារសិទ្ធិ ដែលទទួលស្គាល់ក្នុងលិខិតុបករណ៍សិទ្ធិមនុស្សជាគន្លឹះ និងគោរពតាមនីតិវិធីគតិយុត្តិដែលនៅជាធរមាន)។ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦, មាត្រា ៦ (តម្រូវឱ្យមានការអនុវត្តន៍តឹងរ៉ឹងចំពោះនីត្យានុកូលភាព)។

[37] *សាលដីកាសំណុំរឿង ០០១*, កថាខណ្ឌ ៩០, ៩៨ ដល់១០០ (សម្រេចថា បទល្មើសដែលត្រូវបានចោទប្រកាន់ និងទម្រង់នៃការទទួលខុសត្រូវចាំបាច់ "ត្រូវមានអត្ថិភាពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩" ទើបស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក)។

[38] *សាលដីកាសំណុំរឿង ០០១*, កថាខណ្ឌ ៩៦ (ដកស្រង់ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Ojdanić, និងអ្នកដទៃទៀត*, ICTY, IT-99-37-AR72, "*សាលដីកាលើញត្តិរបស់ Dragoljub Ojdanić ជំទាស់នឹងយុត្តាធិការសហឧក្រិដ្ឋកម្មរួម*", ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣, កថាខណ្ឌ ២១, ៣៧)។

[39] "*សាលដីកាសំណុំរឿង ០០១*", កថាខណ្ឌ ៩៦ (ដកស្រង់ រឿងក្តី *Hadzihasanovic & Kubura*, ICTY, IT-01-47-A, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ ជំទាស់នឹងយុត្តាធិការទាក់ទងការទទួលខុសត្រូវរបស់ថ្នាក់លើ", ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣, កថាខណ្ឌ ៣៤)។

[40] "*សាលដីកាសំណុំរឿង ០០១*", កថាខណ្ឌ ៩៦ (ការដកស្រង់ខាងក្នុង ត្រូវបានលប់ចោល)។

22. គោលការណ៍នីត្យានុកូលភាព ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹងនៅក្នុងយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិល[41]។ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា នីត្យានុកូលភាពគួរមាន "មុខងារក្នុងការរារាំង" នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ "ព្រោះមុខងារនេះរារាំងដល់តុលាការអន្តរជាតិ ឬ តុលាការពិសេស មិនឱ្យអនុវត្តដោយឯកឯងហួសពីយុត្តាធិការរបស់ខ្លួន ដែលមុខងារនេះបានផ្តល់នូវដែនកំណត់ច្បាស់លាស់ថា អំពើណាខ្លះជាបទល្មើសព្រហ្មទណ្ឌ"[42]។ សារៈសំខាន់នៃគោលការណ៍នីត្យានុកូលភាព មិនត្រឹមតែត្រូវបានទទួលស្គាល់ និងផ្តោតការយកចិត្តទុកដាក់ ដោយ អ.វ.ត.ក និងច្បាប់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានទទួលស្គាល់ និងយកចិត្តទុកដាក់ដោយតុលាការអន្តរជាតិ និងតុលាការជាតិដទៃទៀតផង[43]។

## ង. គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ

23. តាមវិធាន២១(១) នៃវិធានផ្ទៃក្នុង ក្របខណ្ឌគតិយុត្តិដែលនៅជាធរមានចំពោះតុលាការ "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព... ឃ) ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ..."។ ស្របជាមួយនឹងវិធាន ២១(១) នៃវិធានផ្ទៃក្នុងដែរ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា "ក្នុងករណីមានវិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"[44]។

[41] Cassese, ទំព័រ ៣៣។

[42] *"សាលដីកាសំណុំរឿង ០០១"*, កថាខណ្ឌ ៩០។

[43] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Lubanga, ICC, ICC-01/04-01/06, *"សេចក្តីសម្រេចលើការបញ្ជាក់ពីបទចោទ"*, ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៧, កថាខណ្ឌ ៣០៣, ភ្ជាប់ជាឧបសម្ព័ន្ធ ២៩។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Delalic និងអ្នកដទៃ*, ICTY, IT-96-21-T, *"សាលក្រម"*, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨, កថាខណ្ឌ៤០២, ភ្ជាប់ជាឧបសម្ព័ន្ធ ៣០។ រឿងក្តី *Kokkinakis តទល់នឹង* Greece, ECHR, no. 14307/88, ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣, កថាខណ្ឌ ៥២, ភ្ជាប់ជាឧបសម្ព័ន្ធ ៣១។ Conseil Constitutionnel, Décision n° 80-127 DC 'Loi renforçant la sécurité et protégeant la liberté des personnes', 20 janvier 1981, កថាខណ្ឌ ៧, ភ្ជាប់ជាឧបសម្ព័ន្ធ ៣២។ Conseil Constitutionnel, Décision n° 98-399 DC, 'Loi relative à l'entrée et au séjour des étrangers en France et au droit d'asile', 05 mai 1998, កថាខណ្ឌ ៧ និង៨, នៅត្រង់ឧបសម្ព័ន្ធ ៣៣។

[44] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៣៨។

24. ក្នុងការពិភាក្សាអំពីវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក បាន សម្រេចថា "បញ្ហាទាក់ទងនិងវិធាន ២១ នៃវិធានផ្ទៃក្នុង នៅក្នុងផ្នែក វិមតិសង្ស័យ ត្រូវបានជា ប្រយោជន៍ដល់ជនជាប់ចោទ ដែលបណ្តាលមកពីសច្ចធារណ៍នៃនិរទោសនោះ ត្រូវបានធានា ការពារដោយរដ្ឋធម្មនុញ្ញកម្ពុជា ហើយមានមុខងារចម្បងដើម្បីចង្អុលបង្ហាញនូវការសម្រេចមួយ ក្នុងករណីដែលមានវិមតិសង្ស័យលើអង្គហេតុដែលមិនអាចដោះស្រាយបានដោយសារភ័ស្តុតាង។ ចំពោះវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដែលត្រូវអនុវត្តចំពោះទ្វេគ្រោះ អំពី អត្ថន័យរបស់ច្បាប់ ចំណុចនេះត្រូវកម្រិតតែត្រឹមវិមតិសង្ស័យ ដែលនៅសេសសល់បន្ទាប់ពីការបក ស្រាយច្បាប់ហើយ"[45]។

25. ពាក់ព័ន្ធការបកស្រាយច្បាប់ទំនៀមទម្លាប់អន្តរជាតិ អង្គបុរេជំនុំជម្រះបានសម្រេចថា "ក្នុងករណី មិនមានបង្ហាញច្បាស់លាស់នូវការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់* ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលបង្ហាញពីការបំបែកលក្ខខណ្ឌតម្រូវជម្លោះប្រដាប់អាវុធពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាម ច្បាប់ទំនៀមទម្លាប់អន្តរជាតិ នោះគោលការណ៍វិមតិសង្ស័យ "នឹងបានជាប្រយោជន៍ដល់ជនជាប់ ចោទ" តម្រូវថាភាពស្រពិចស្រពិលនានាត្រូវដោះស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ"[46]។ គោលការណ៍នីត្យានុកូលភាព និងគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់

---

[45] សំណុំរឿង០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក (04), "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់ ខៀវ សំផន សុំឱ្យដោះលែងភ្លាមៗ", ឯកសារ E50/3/1, ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១១, កថាខណ្ឌ ៣១, ភ្ជាប់ជាឧបសម្ព័ន្ធ ៣៤ (ការដកស្រង់ខាងក្នុង ត្រូវបានលុបចោល)។

[46] សំណុំរឿង០០២/១៩-០៩-២០០៧ អ.វ.ត.ក/ក.ស.ច.ស (អបជ ១៤៥ និង១៤៦), "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ", ឯកសារ D427/2/15, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១, កថាខណ្ឌ ១៣៤ ដល់១៤៤, ភ្ជាប់ជាឧបសម្ព័ន្ធ ៣៥ (សម្រេចថាទោះបីជាលក្ខខណ្ឌតម្រូវ ជម្លោះប្រដាប់អាវុធ គឺជាផ្នែកឬមិនមែនជាផ្នែក នៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺនៅតែមិនច្បាស់លាស់គ្រប់គ្រាន់ដើម្បីចោទប្រកាន់ជនជាប់ចោទ)។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Akayesu*, ICTR, ICTR-96-4-T, "*សាលក្រម*", ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨, កថាខណ្ឌ ៣១៩, ភ្ជាប់ជាឧបសម្ព័ន្ធ ៣៦ (បញ្ជាក់ថា "គោលការណ៍គតិយុត្តិទូទៅចែងថា ចំពោះបញ្ហាព្រហ្មទណ្ឌ ផ្នែកដែលបានជាប្រយោជន៍ដល់ជនជាប់ចោទ គួរត្រូវបានជ្រើសរើស")។

ចោទ ដូចលើកឡើងដោយអង្គជំនុះជម្រះតុលាការកំពូល និងអង្គបុរេជំនុំជម្រះ ស្របគ្នានឹងមាត្រា ២២ នៃលក្ខន្តិកៈទីក្រុងរ៉ូម[47]។

## III. ទឡ្ហីករណ៍

26. តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការមួយទៅលើសមាជិកកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន មិនអាចចាត់ទុកថាជាការវាយប្រហារទៅលើប្រជាជនស៊ីវិលឡើយ ដូច្នេះហើយ មិនអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។ ទីមួយ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មិនមានភស្តុតាងនៃការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់* ដែលបញ្ចូលយុទ្ធជនទៅក្នុងវិសាលភាពនៃ "ប្រជាជនស៊ីវិល" ផ្ទុយទៅវិញ ការអនុវត្តរបស់រដ្ឋដែលមានស្រាប់បង្ហាញពីការដកចេញយុទ្ធជន។ ទីពីរ ការយកនិយមន័យនៃ "ប្រជាជនស៊ីវិល" ដែលហួសពីអត្ថន័យទូទៅ បានរំលោភបំពានទៅលើគោលការណ៍នីត្យានុកូលភាព។ ចុងក្រោយ ប្រសិនបើមិនមានភស្តុតាងនៃការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់* ដែលគាំទ្រថា ការវាយប្រហារដោយរដ្ឋ ឬអង្គការទៅលើសមាជិកកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន បង្កើតបានជាការវាយប្រហារទៅលើ ប្រជាជនស៊ីវិល ដូច្នេះគោលការណ៍មានវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ តម្រូវឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិដោះស្រាយភាពស្រពិចស្រពិលនេះដោយផ្តល់ប្រយោជន៍ដល់ជនត្រូវចោទ។

### ក. មានភស្តុតាងនៃការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់* ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលបង្ហាញថា "ប្រជាជនស៊ីវិល" មិនរាប់បញ្ចូលយុទ្ធជនទេ

27. ការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់* ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បញ្ជាក់ថា ឃ្លា "ប្រជាជនស៊ីវិល" មិនគ្រប់ដណ្តប់ដល់យុទ្ធជនឡើយ។ ទីមួយ អត្ថន័យទូទៅនៃពាក្យ"ប្រជាជនស៊ីវិល" នៅក្នុងអត្ថបទច្បាប់ពាក់ព័ន្ធនៅមុនឆ្នាំ១៩៧៥មិនបានរួមបញ្ចូលយុទ្ធជនឡើយ ហើយការបកស្រាយឃ្លាថាបញ្ចូលកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋឬអង្គការ នឹងពង្រីកឃ្លានេះចេញឆ្ងាយពីអត្ថ

---

[47] លក្ខន្តិកៈទីក្រុងរ៉ូម, មាត្រា ២២(២) ("និយមន័យនៃឧក្រិដ្ឋកម្ម គួរត្រូវបានវិភាគដោយតឹងរ៉ឹង ហើយមិនត្រូវពង្រីកតាមន័យដូចឡើយ។ ក្នុងករណីមានភាពមិនច្បាស់លាស់ និយមន័យត្រូវបកស្រាយជាប្រយោជន៍ដល់បុគ្គលដែលកំពុងត្រូវបានស៊ើបអង្កេត ចោទប្រកាន់ ឬផ្តន្ទាទោស")។

ន័យទូទៅរបស់វា ដូច្នេះហើយនឹងរំលោភបំពានទៅលើវិធាននៃការបកស្រាយឱ្យបានតឹងរ៉ឹង។ ទីពីរ យុត្តិសាស្ត្រនៅមុន និងក្រោយអំឡុងពេលដែលកំពុងចោទជាបញ្ហា បានកំណត់ថា សមាជិកកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬអង្គការ មិនអាចចាត់ទុកថាជា "ប្រជាជនស៊ីវិល" ឡើយនៅក្នុងឆ្នាំពី១៩៧៥ ដល់ឆ្នាំ១៩៧៩។

i. ***អត្ថន័យទូទៅនៃ "ប្រជាជនស៊ីវិល" នៅក្នុងអត្ថបទច្បាប់មុនឆ្នាំ ១៩៧៥ ដែលពាក់ព័ន្ធ មិនបានបញ្ចូលយុទ្ធជនឡើយ ហើយការបកស្រាយបែបនេះនឹងពង្រីកឃ្លាឱ្យហួសឆ្ងាយពីអត្ថន័យទូទៅ***

28. ការបញ្ចូលយុទ្ធជន ដូចជាកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនរបស់អ្នកវាយប្រហារ ទៅក្នុងនិយមន័យនៃ "ប្រជាជនស៊ីវិល" បានពង្រីកឃ្លាឱ្យហួសពីអត្ថន័យទូទៅរបស់វា។ អត្ថន័យទូទៅនៃ "ប្រជាជនស៊ីវិល" នៅក្នុងអត្ថបទច្បាប់មុនឆ្នាំ ១៩៧៥ ដែលពាក់ព័ន្ធកម្រិតត្រឹមបុគ្គលដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬបើមិនដូច្នេះទេត្រូវបានទទួលស្គាល់ថាជាយុទ្ធជន[48]។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនបានញែកគ្នារវាងយុទ្ធជនរបស់ខ្មាំង ឬកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនរបស់អ្នកវាយប្រហារឡើយ។ ប៉ុន្តែច្បាប់ទំនៀមទម្លាប់អន្តរជាតិបានហាមឃាត់មិនឱ្យចាត់ទុកយុទ្ធជនជាទូទៅថាជាជនស៊ីវិល សម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[49]។

29. យោងតាមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក នៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ "អត្ថន័យទូទៅនៃពាក្យ"civilian"(ជាភាសាអង់គ្លេស) និង"civil"(ជាភាសាបារាំង) រួមមានបុគ្គលទាំងឡាយណាដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ"[50]។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា "ប្រជាជនស៊ីវិលរាប់បញ្ចូលនូវបុគ្គលទាំងឡាយណា ដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់

---

[48] Cassese, ទំព័រ ១០១ ដល់១០២ (បញ្ជាក់ថា "ច្បាស់ណាស់ដែលថា [មាត្រា ៦(គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ] មិនបានចែងដល់យុទ្ធជន")។

[49] *សូមមើល* Mohamed Elewa Badar, *ពីធម្មនុញ្ញ Nuremberg ដល់លក្ខន្តិកៈទីក្រុងរ៉ូម៖ ការកំណត់និយមន័យលើធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*, 5 San Diego Int'l L.J. 73, (2004), ទំព័រ ១០១ ដល់១០២, ភ្ជាប់ជាឧបសម្ព័ន្ធ ៣៧ (បានពន្យល់ពីគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាម នៃអង្គការសហប្រជាជាតិ ដែលបញ្ជាក់ដោយយោងទៅរកមាត្រា ៦(គ) ថា ពាក្យ "ប្រជាជនស៊ីវិល" ហាក់ដូចជាបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានកម្រិតត្រឹមតែអំពើអមនុស្សធម៌ ដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងជនស៊ីវិល ដែលខុសពីសមាជិកកងកម្លាំងប្រដាប់អាវុធ ....")។

[50] "*សាលក្រមលើសំណុំរឿង ០០២/០១*", កថាខណ្ឌ ១៨៥។

អាវុធ ឬមិនមែនជាជនត្រូវបានទទួលស្គាល់ថាជាយុទ្ធជន"[51]។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា អត្ថន័យទូទៅនៃ"ជនស៊ីវិល" ស្របជាមួយនឹងនិយមន័យដែលមានចែងក្នុងមាត្រា ៥០ នៃពិធីសារបន្ថែម I ដែលតុលាការ*មិនអចិន្ត្រៃយ៍*នានាបានប្រើប្រាស់ដោយថាបានឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិក្រោយឆ្នាំ១៩៧៧[52]។

30. ក្នុងការអនុវត្តអត្ថន័យទូទៅនៃពាក្យ "ជនស៊ីវិល" អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានសម្រេចថា ទាហាន*ដែលបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ* មិនត្រូវបានចាត់ទុកថាជា "ជនស៊ីវិល" នោះទេ ផ្អែកតាមគោលបំណងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[53]។ អង្គជំនុំជម្រះសាលាដំបូងពន្យល់ដូចតទៅ៖

> នៅក្នុងការកំណត់អំពីឋានៈរបស់បុគ្គលណាម្នាក់ ថាជាជនស៊ីវិល ឬមិនមែនជាជនស៊ីវិល ស្ថានភាពជាក់លាក់របស់បុគ្គលនោះ នៅក្នុងពេលដែលមានបទឧក្រិដ្ឋកើតឡើង មិនអាចកំណត់អំពីឋានៈទាំងនេះបានឡើយ។ សមាជិកនៃអង្គការប្រដាប់អាវុធ មិនត្រូវទទួលបានឋានៈជាជនស៊ីវិលនោះឡើយ ទោះបីជាគាត់មិនកាន់អាវុធ ឬមិនបានចូលរួមនៅក្នុងការប្រយុទ្ធ ក្នុងពេលដែលមានការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះក៏ដោយ[54]។

ហេតុដូច្នេះមេធាវីការពារក្តីសូមលើកឡើងថា ប្រសិនបើទាហានមិនមានអាវុធ ឬទាហាន*ដែលបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ* មិនត្រូវបានការពារតាមនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ទេ ចំណុចនេះត្រូវបានចាត់ទុកថាមិនសមហេតុផល ឬមិនស៊ីសង្វាក់គ្នា ក្នុងការសម្រេចថា កងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន របស់អ្នកវាយប្រហារ ត្រូវបានការពារ។

---

[51] "*សាលក្រមលើសំណុំរឿង ០០២/០១*", កថាខណ្ឌ ១៨៥។

[52] "*សាលក្រមលើសំណុំរឿង ០០២/០១*", កថាខណ្ឌ ១៨៥។ *រដ្ឋអាជ្ញា តទល់នឹង Blaškić* , IT-95-14-A, *សាលដីកា*, ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០០៤, កថាខណ្ឌ ១១០, ភ្ជាប់ជាឧបសម្ព័ន្ធ ៣៨។

[53] "*សាលក្រមលើសំណុំរឿង ០០២/០១*", កថាខណ្ឌ ១៨៦។ *Blaškić*, កថាខណ្ឌ ១១៤ ដល់១១៥ (សម្រេចថាអង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងក្នុងការសម្រេចថា ស្ថានភាពជាក់លាក់របស់ជនរងគ្រោះ នៅពេលមានឧក្រិដ្ឋកម្មនោះ គឺជាកត្តាកំណត់ពីឋានៈជាជនស៊ីវិល ឬមិនមែនជាជនស៊ីវិល)។

[54] "*សាលក្រមលើសំណុំរឿង ០០២/០១*", កថាខណ្ឌ ១៨៦។

31. អត្ថន័យទូទៅនៃ "ប្រជាជនស៊ីវិល" ក៏ចាំបាច់ត្រូវពិនិត្យមើលក្នុងបរិបទនៃកម្មវត្ថុ និងគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែរ។ វាមានភាពច្បាស់លាស់នៅក្នុងអត្ថបទ និង ការងារត្រៀម (*travaux préparatoires)* ទាក់ទងលិខិតុបករណ៍ពាក់ព័ន្ធមុនឆ្នាំ១៩៧៥ ដែលថា អ្នកព្រាងលិខិតុបករណ៍ទាំងអស់នេះ មិនមានចេតនាឲ្យ "ជនស៊ីវិល" គ្រប់ដណ្ដប់ទៅលើគ្រប់បុគ្គលទាំងអស់ ហើយក៏មិនមានចេតនាបង្កើតករណីលើកលែងដែលថា កងកម្លាំងប្រដាប់អាវុធរបស់អ្នកវាយប្រហារត្រូវបានគ្រប់ដណ្ដប់ផងដែរនោះទេ[55]។

32. ដូចដែលបានពន្យល់ក្នុងផ្នែកទីII លិខិតុបករណ៍គតិយុត្ត ដែលកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅមុន និងក្រោយឆ្នាំ១៩៧៥ ដល់១៩៧៩ សុទ្ធតែបានបញ្ចូលលក្ខខណ្ឌតម្រូវស្ដីពីជនស៊ីវិល ដោយមិនមានការព្រមាន និងជំទាស់ណាមួយឡើយ[56]។ ផ្ទុយទៅវិញ លក្ខខណ្ឌតម្រូវ និងអត្ថន័យទូទៅរបស់វា ត្រូវបានទទួលយកយ៉ាងទូលំទូលាយ។ ចំណុចនេះក៏ត្រូវបានបង្ហាញផងដែរនៅក្នុងយុត្តិសាស្ត្រ និងច្បាប់ជាតិ ក្រោយសម័យ Nuremberg ដែលទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ុន្តែមិនមានការដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិក្រៅពីទៅលើ "ជនស៊ីវិល"ឡើយ[57]។

33. ប្រសិនបើអ្នកតាក់តែងសេចក្ដីព្រាងលិខិតុបករណ៍ទាំងនោះ មានចេតនាចង់ដកចេញលក្ខខណ្ឌតម្រូវស្ដីពីជនស៊ីវិល ពួកគេគួរតែបានដកចេញ ដូចដែលអ្វីដែលពួកគេបានធ្វើចំពោះលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងជម្លោះប្រដាប់អាវុធ នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឬលក្ខខណ្ឌតម្រូវស្ដីពីភាពរើសអើង ដែលលេចឡើងក្នុងនិយមន័យ

---

[55] Cassese, ទំព័រ ១០២។

[56] *ឧទាហរណ៍,* ធម្មនុញ្ញតុលាការយោធាអន្តរជាតិ, មាត្រា ៦(គ)។ ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង, មាត្រា II(ក)។ ធម្មនុញ្ញទីក្រុងតូក្យូ, មាត្រា ៥(គ)។ គោលការណ៍ Nuremberg, គោលការណ៍ ៦(គ); សេចក្ដីព្រាងក្រមឆ្នាំ១៩៥១, មាត្រា ២ (១០)។ អនុសញ្ញាស្ដីពីការមិនអនុវត្តន៍ អាជ្ញាយុកាល។ ករណីលើកលែងតែមួយគត់ ដែលកំណត់បង្ហាញដោយមេធាវីការពារក្ដី គឺនៅក្នុងសេចក្ដីព្រាងច្បាប់ឆ្នាំ ១៩៩១ នៃឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសុវត្ថិភាពមនុស្សជាតិ ដែលត្រូវបានរិះគន់យ៉ាងខ្លាំង។

[57] *ឧទាហរណ៍,* ក្រមព្រហ្មទណ្ឌបារាំង, មាត្រា ២១២-១។ Cass. Crim., ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៥, No 14-86850, ភ្ជាប់ជាឧបសម្ព័ន្ធ ៣៩ ('…qu'en l'espèce, les deux incriminations présentent des éléments constitutifs distincts, visent des valeurs protégées distinctes et des intentions criminelles différentes ; que le crime de génocide vise à protéger des groupes déterminés de leur destruction totale ou partielle ; que les autres crimes contre l'humanite visent quant à eux à protéger " un groupe de population civile 'contre des atteintes à leur intégrité physique ou psychique, sans qu'il ne soit requis que les actes visés mettent à exécution un plan dont la finalité est sa destruction totale ou partielle')។

របស់តុលាការ ICTR តែមិនមាននៅក្នុងនិយមន័យរបស់តុលាការ ICTY ទេ[58]។ ដូចគ្នានេះដែរ ប្រសិនបើអ្នកតាក់តែងសេចក្តីព្រាងមានចេតនាការពារបុគ្គលទាំងអស់ ដោយមិនគិតពីឋានៈរបស់ពួកគេថាជាជនស៊ីវិល ឬទាហាននោះ ពេលនោះពួកគេនឹងបញ្ជាក់ដូច្នេះនៅក្នុងអត្ថបទច្បាប់ហើយ។

34. លើសពីនេះទៀត ច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានលេចចេញឡើងជាប្រវត្តិសាស្ត្រ ដើម្បីការពារប្រជាជនស៊ីវិល មិនមែនអ្នកដែលជាប់ពាក់ព័ន្ធជាមួយខ្មាំង ឬដែលត្រូវបានការពារដោយច្បាប់មនុស្សធម៌អន្តរជាតិពីការវាយប្រហារជាទ្រង់ទ្រាយធំ និងជាប្រព័ន្ធឡើយ[59]។ លក្ខខណ្ឌតម្រូវស្តីពីប្រជាជនស៊ីវិល គឺជាផ្នែកមួយនៃនិយមន័យចាប់តាំងពីពេលតាក់តែងច្បាប់ សម្រាប់ឧក្រិដ្ឋកម្មនេះនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិមកម្ល៉េះ[60]។ ការយោងទៅ "ជនស៊ីវិល" គឺជាផ្នែកបង្កើតថ្មីក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់ធម្មនុញ្ញតុលាការយោធាអន្តរជាតិ បើប្រៀបធៀបទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ដោយសារតែវាអនុញ្ញាតឲ្យមានការចោទប្រកាន់ចំពោះអំពើដែលប្រព្រឹត្តទៅលើប្រជាជនផ្ទាល់របស់ចារី ដែលមិនត្រូវបានការពារដោយច្បាប់ស្តីពីជម្លោះប្រដាប់អាវុធ[61]។ តាមពិតទៅឃ្លា "ប្រជាជនស៊ីវិល" គឺជា*មូលហេតុសំខាន់*បំផុតរបស់ធម្មនុញ្ញតុលាការយោធាអន្តរជាតិ[62]។

---

[58] *ឧទាហរណ៍* លក្ខន្តិកៈតុលាការ ICTY មាត្រា ៥។ លក្ខន្តិកៈតុលាការ ICTR, មាត្រា ៣។ លក្ខន្តិកៈទីក្រុងរ៉ូម, មាត្រា ៧(១)។

[59] Cassese, ទំព័រ 101-102 ('ចំពោះពាក្យ "ណាមួយ" ច្បាស់ណាស់ថាតាមអត្ថបទបទប្បញ្ញត្តិ និងតាមប្រវត្តិនៃមាត្រា ៦(គ) ពាក្យនេះមានបំណងគ្រប់ដណ្តប់លើប្រជាជនស៊ីវិល មិនមែនអ្នកដែលជាប់ទាក់ទងជាមួយខ្មាំង ដែលត្រូវបានការពាររួចហើយដោយវិធានប្រពៃណីនៃច្បាប់ស្តីពីសង្គ្រាម... ចំពោះពាក្យជនស៊ីវិលវិញ ច្បាស់ណាស់ថាពាក្យនេះមិនគ្រប់ដណ្តប់លើយុទ្ធជនឡើយ"); Van Schaack, ទំព័រ ៨០៧ ('អ្វីដែលជាការធ្វើបដិវត្តពិតប្រាកដ ចំពោះទស្សនៈឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺថាទោះបីជាអំពើដែលត្រូវបានហាមឃាត់ មិនប្រែប្រួលខ្លាំងពីឧក្រិដ្ឋកម្មសង្គ្រាម ជាប្រពៃណីក៏ដោយ ប៉ុន្តែចំណាត់ថ្នាក់នៃជនរងគ្រោះ ដែលត្រូវបានការពារដោយការហាមឃាត់ចំនួនពីរ គឺមិនប្រែប្រួលខ្លាំងក្លាឡើយ")។

[60] Goran Sluiter, *"ធាតុផ្សំមូលដ្ឋាន" នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងយុត្តិសាស្ត្ររបស់តុលាការមិនចំពោះកិច្ចរបស់អង្គការសហប្រជាជាតិ*, នៅក្នុង Leila Nadya Sadat (ed.), "ការជម្រុញអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" (Cambridge University Press: Cambridge 2011), ទំព័រ ២០ ដល់២៤, ភ្ជាប់ជាឧបសម្ព័ន្ធ ៤០ ជាឯកសារទម្រង់ Word format។

[61] Sluiter, ទំព័រ ២០។ Joakim Dungel, *កំណត់និយមន័យជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ: Martic និងតុលាការព្រហ្មទណ្ឌអន្តរជាតិ*, Leiden Journal of Int'l Law, ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩, ទំព័រ ៧២៩, ភ្ជាប់ជាឧបសម្ព័ន្ធ៤១ ('ដោយតម្រូវថា អំពើដែលបានចែង ត្រូវបានប្រព្រឹត្តឡើងប្រឆាំង"ប្រជាជនស៊ីវិលណាមួយ" នោះ អ្នកតាក់តែងសេចក្តីព្រាងធម្មនុញ្ញ Nuremberg បានដោះស្រាយបញ្ហានៃឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តដោយរដ្ឋ ទៅលើប្រជាជនផ្ទាល់ខ្លួន")។ Van Schaack, ទំព័រ ៧៨៩ ដល់៧៩០ (បញ្ជាក់ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ "ចែងពី

35. មេធាវីការពារក្ដីសូមលើកឡើងថា ការបកស្រាយពាក្យ "ប្រជាជនស៊ីវិល" ឱ្យហួសពីអត្ថន័យទូទៅនឹងធ្វើឱ្យប៉ះពាល់ដល់ការបែងចែករវាងជនស៊ីវិល និងអ្នកមិនមែនជាជនស៊ីវិល នៅក្នុងច្បាប់អន្តរជាតិ។ ការបែងចែកនេះគឺជាគោលការណ៍មូលដ្ឋាននៃច្បាប់មនុស្សធម៌អន្តរជាតិ[63]។ បើគ្មានចំណុចនេះទេ ខ្សែបន្ទាត់ខណ្ឌចែកឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម នឹងក្លាយជាមិនច្បាស់ ហើយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនឹងក្លាយជាការពង្រីកនៃឧក្រិដ្ឋកម្មសង្គ្រាម ដែលមិនស៊ីសង្វាក់ជាមួយគោលដៅរបស់វាក្នុងការការពារជនស៊ីវិលឡើយ[64]។

36. ដោយផ្អែកទៅលើមូលដ្ឋានខាងលើ មានភស្តុតាងបង្ហាញពីការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់* នៅក្នុងឆ្នាំ ១៩៧៥ ដល់១៩៧៩ ដែលដកយុទ្ធជនចេញពីនិយមន័យនៃ "ប្រជាជនស៊ីវិលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"។ ការបកស្រាយឃ្លានេះឱ្យរួមបញ្ចូលកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនរបស់អ្នកវាយប្រហារ នឹងពង្រីកអត្ថន័យឱ្យហួសពីអត្ថន័យទូទៅរបស់វា ដូចដែលបានអនុវត្តនៅក្នុងការអនុវត្តកម្រិតជាតិ និងកម្រិតអន្តរជាតិ នៅក្នុងការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ចំណុចនេះនឹងត្រូវពន្យល់បន្ថែមទៀតនៅផ្នែកខាងក្រោម៖

### *ii. យុត្តិសាស្ត្រមុនឆ្នាំ១៩៧៥ បានអនុម័តយកអត្ថន័យទូទៅនៃពាក្យ"ប្រជាជនស៊ីវិល" ហើយមិនរួមបញ្ចូលយុទ្ធជនទៅក្នុងនិយមន័យឡើយ*

37. យុទ្ធសាស្ត្រមុនឆ្នាំ ១៩៧៥ បង្ហាញភស្តុតាងពីការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់* ដែលបានអនុម័តយកអត្ថន័យទូទៅនៃពាក្យ "ប្រជាជនស៊ីវិល" ហើយដកពាក្យយុទ្ធជនចេញពីនិយមន័យ។ ជាឧទាហរណ៍ នៅក្នុងរឿងក្ដី *Pilz* តុលាការកំពូលពិសេសរបស់ប្រទេសហូឡង់បានសម្រេចថា ការធ្វើឃាតទាហានអាល្លឺម៉ង់ ដែលមានសញ្ជាតិហូឡង់ផងដែរនោះ ដោយវេជ្ជបណ្ឌិតអាល្លឺម៉ង់ ដែលបម្រើការងារនៅក្នុងកងទ័ពអាល្លឺម៉ង់ ដែលត្រួតត្រាប្រទេសហូឡង់ មិនអាចបង្កើតជាឧក្រិដ្ឋ

---

អំពើដែលបានប្រព្រឹត្តដោយចារីណាហ្ស៊ីទៅលើជនរងគ្រោះអាល្លឺម៉ង់ ដែលមានសញ្ជាតិដូចអ្នកគាប់សង្កត់ពួកគេ ឬទៅលើប្រជាជននៃរដ្ឋដែលជាសម្ព័ន្ធមិត្តរបស់អាល្លឺម៉ង់")។

[62] Sluiter, ទំព័រ ២០។

[63] *Martic*, កថាខណ្ឌ ២៩៩ ('លក្ខណៈជាសារវន្តនៃសញ្ញាណជនស៊ីវិល នៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ តម្រូវមិនឱ្យផ្ដល់នូវអត្ថន័យផ្សេង" តាមមាត្រា ៣ និងមាត្រា ៥ នៃលក្ខន្តិកៈតុលាការ ICTY)។

[64] *Martic*, កថាខណ្ឌ ២៩៩។ Dungel, ទំព័រ ៧៣៥។

កម្មប្រឆាំងមនុស្សជាតិទេ ព្រោះជនរងគ្រោះ "មិនមែនជាផ្នែកមួយនៃប្រជាជនស៊ីវិល នៅក្នុងតំបន់ដែលត្រូវត្រួតត្រាឡើយ"[65]។

38. តាមពិតទៅ ឧទាហរណ៍មួយចំនួននៃយុត្តិសាស្ត្រអន្តរជាតិមុនឆ្នាំ ១៩៧៥ ដែលក្នុងនោះ តុលាការបានពង្រីកការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទៅលើអ្នកដែលមិនមែនជាជនស៊ីវិល បានអនុវត្តបែបនេះក្នុងកម្រិតកំណត់ខ្លាំងណាស់។ ក្នុងរឿងក្តីចំនួនបី តុលាការកំពូលអាល្លឺម៉ង់នៅក្នុងតំបន់ដែលត្រួតត្រាដោយអង់គ្លេស បានសម្រេចថា យោធាអាចជាជនរងគ្រោះជាបុគ្គលនៃបទល្មើសជាមូលដ្ឋានរបស់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[66]។ ប៉ុន្តែបញ្ហានេះគឺខុសពីបញ្ហាមាននៅចំពោះមុខ។ ទោះបីជាតុលាការទទួលស្គាល់ឋានៈរបស់ជនរងគ្រោះ នៅក្នុងរឿងក្តីនីមួយៗក៏ដោយ តែវាមិនមែនជាកត្តាសំខាន់នៅក្នុងសេចក្តីសម្រេចរបស់តុលាការឡើយ[67]។ គួរឲ្យកត់សម្គាល់ដែរនោះ តុលាការមិនបានឈានដល់ការសម្រេចថា ការវាយប្រហារសំដៅលើទាហាន អាចជាការវាយប្រហារសំដៅលើប្រជាជនស៊ីវិលឡើយ[68]។ ចំណុចនេះក៏ត្រឹមត្រូវផងដែរសម្រាប់យុត្តិសាស្ត្រអន្តរជាតិក្រោយឆ្នាំ១៩៧៩[69]។

---

[65] Cassese, ទំព័រ ១០២ (ដកស្រង់ *Pilz,* តុលាការកំពូលពិសេសរបស់ហូឡង់, សាលក្រមថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៥៩, នៅក្នុង *Nederlandse Jurisprudentie*, 1950, no. 681, 1209-11)។

[66] Cassese, ទំព័រ ១០២ ដល់១០៣, ជើងទំព័រ ៤៤ ដល់៤៦ (យោងទៅរក *រឿងក្តី R.* ។ *រឿងក្តី P. និងអ្នកដទៃទៀត និងរឿងក្តី H*)។

[67] Cassese, ទំព័រ ១០២ ដល់១០៣។

[68] Cassese, ទំព័រ ១០២ ដល់១០៣, ជើងទំព័រ ៤៤ ដល់៤៦។

[69] រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង* Mrkšić, ICTY, IT-95-13/1-A, *"សាលដីកា"*, ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៩, កថាខណ្ឌ ៣២, ភ្ជាប់ជាឧបសម្ព័ន្ធ ៤២ ("អាស្រ័យហេតុនេះ ចំពោះឋានៈជនស៊ីវិលរបស់ជនរងគ្រោះ ចំនួនជនស៊ីវិល និងចំណែកនៃជនស៊ីវិលនៅក្នុងប្រជាជនស៊ីវិល គឺជាកត្តាពាក់ព័ន្ធចំពោះការសម្រេច ថាតើលក្ខខណ្ឌតម្រូវមូលដ្ឋាន នៃមាត្រា៥ នៃលក្ខន្តិកៈដែលថា ការវាយប្រហារសំដៅលើ "ប្រជាជនស៊ីវិល" ត្រូវបានបំពេញ គឺមិនមានលក្ខខណ្ឌតម្រូវ ឬក៏វាជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលថាជនរងគ្រោះនៃឧក្រិដ្ឋកម្មមូលដ្ឋាន គឺជា "ជនស៊ីវិល")។ *Martic,* កថាខណ្ឌ ៣០៣ ដល់៣១២ (សម្រេចថាប្រសិនបើការវាយប្រហារ សំដៅលើ "ប្រជាជនស៊ីវិល" គឺមិនចាំបាច់ត្រូវកំណត់ថា ជនរងគ្រោះម្នាក់ៗ នៃឧក្រិដ្ឋកម្មជាមូលដ្ឋាន ត្រូវបានប្រព្រឹត្តិដែលជាផ្នែកនៃការវាយប្រហារនោះ គឺជា"ជនស៊ីវិល"ឡើយ)។ ហេតុដូច្នេះតុលាការ ICTY បានអះអាងដោយមានប្រសិទ្ធិភាពថា សម្រាប់គោលបំណងនៃការកំណត់ធាតុផ្សំមូលដ្ឋាន នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, រដ្ឋអាជ្ញានៅតែចាំបាច់ត្រូវបង្ហាញភស្តុតាងថា "ការវាយប្រហារ" គឺសំដៅលើប្រជាជនស៊ីវិល មិនមែនសំដៅលើយុទ្ធជនឡើយ។

39. សរុបសេចក្តីមក សូម្បីតែរហូតមកដល់បច្ចុប្បន្ននេះ មិនមានការចាប់ផ្តើមការបង្កើតឡើងណាមួយនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទោះជាការអនុវត្តរបស់រដ្ឋ ឬ*ទស្សនៈច្បាប់* ដែលបញ្ជាក់ថា "ប្រជាជនស៊ីវិល" អាចរួមទាំងយុទ្ធជននោះទេ។ ការពង្រីកធំធេងចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបែបនេះ មិនអាចធ្វើឡើងដោយស្រួលៗបានឡើយ ហើយប្រាកដណាស់ថាមិនអាចផ្អែកទៅលើរឿងក្តីតែមួយ ឬការអនុវត្តរបស់រដ្ឋមួយចំនួននោះទេ។

40. ទោះជាយ៉ាងនេះក្តី ប្រសិនបើសហចៅក្រមស៊ើបអង្កេតអន្តរជាតិស្វែងរកគោលការណ៍ណែនាំនៅក្នុងរឿងក្តីដាច់តែឯង បើទោះបីជាមិនមែនជាវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិណាមួយនោះប្រាកដណាស់ថា មានតែជនរងគ្រោះជាយុទ្ធជនដាច់តែឯងប៉ុណ្ណោះ ក្នុងចំណោមប្រជាជនស៊ីវិលដែលជាគោលដៅធំទូលាយ ដែលអាចស្ថិតក្នុងវិសាលភាពនៃការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើចំនួនទាហានជាច្រើនត្រូវទទួលរងការវាយប្រហារពេលនោះការវាយប្រហារបែបនេះមិនអាចចាត់ទុកថាជាការវាយប្រហារ សំដៅលើប្រជាជនស៊ីវិលឡើយ ដោយសារតែការវាយប្រហារជាទ្រង់ទ្រាយធំ មិនត្រូវបានចាត់ទុកថាជាការវាយប្រហារសំដៅលើប្រជាជនស៊ីវិលឡើយ។ ជាការពិត បញ្ហានេះមិនមែនជាស្ថានភាពដែលបណ្តាលឲ្យមានសំណើសុំឲ្យមានសារណានេះឡើយ។

**ខ. ជនត្រូវចោទមិនអាចប្រមើលមើលដឹងថាជាបទល្មើស និងមិនអាចដឹងថាមានច្បាប់ចែងឡើយដែលថា ការវាយប្រហាររបស់រដ្ឋ ឬអង្គការទៅលើ កងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន អាចចាត់ទុកថាជាការវាយប្រហារទៅលើប្រជាជនស៊ីវិលនោះ**

41. គោលការណ៍នីត្យានុកូលភាពតម្រូវថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវអនុម័តយកការបកស្រាយ"ប្រជាជនស៊ីវិល" ដែលស៊ីសង្វាក់គ្នានឹងអត្ថន័យទូទៅនៃពាក្យនេះ។ ការអនុម័តយកការបកស្រាយដែលឃ្លាតចាកឆ្ងាយពីអត្ថន័យទូទៅ នឹងរំលោភបំពានទៅលើគោលការណ៍នេះ។ បើទោះបីជាត្រូវបានចាត់ទុកថាមិនសមហេតុផល ដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិការពារជនស៊ីវិល តែមិនការពារទាហាន ទាំងនៅក្នុងពេលសន្តិភាព ឬពេលមានជម្លោះក៏ដោយ តែចំណុចនេះមិនអាចធ្វើយុត្តិកម្មដល់ការពង្រីកអត្ថន័យ "ប្រជាជនស៊ីវិល" រហូតដល់កម្រិតមួយដែល គ្មានមនុស្សណាម្នាក់អាចនឹកគិតដល់ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលត្រូវសម្របការប្រព្រឹត្តរបស់ខ្លួនឲ្យត្រូវតាមចំណុចនេះឡើយ។

42. លើសពីនេះទៀត អង្គហេតុដែលថា យុត្តិសាស្ត្រក្រោយឆ្នាំ១៩៧៩ ជាឧទាហរណ៍ យុត្តិសាស្ត្រនៅតុលាការ ICTY[70] ប្រឈមជាមួយនឹងបញ្ហាដូចជា ថាតើ ទាហាន*ដែលបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ* អាចស្ថិតក្នុងក្រុម“ប្រជាជនស៊ីវិល” ដែរឬយ៉ាងណានោះ បានបង្ហាញច្បាស់លាស់ណាស់ថា ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការទៅលើកងកម្លាំងប្រដាប់ផ្ទាល់ខ្លួន មិនអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។ ការទទួលខុសត្រូវព្រហ្មទណ្ឌ មិនអាចត្រូវបានប្រមើមើលឃើញ ឬមិនអាចដឹងដោយជនត្រូវចោទ ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឡើយ។

**គ. ប្រសិនបើមិនមានការអនុវត្តរបស់រដ្ឋ ឬ*ទស្សនៈច្បាប់* ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ទាក់ទងថាតើ “ប្រជាជនស៊ីវិល” គ្របដណ្តប់ដែរឬអត់ ទៅលើកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន របស់រដ្ឋ ឬអង្គការនោះ គោលការណ៍វិមតិសង្ស័យ នឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ កំណត់ថា ភាពមិនច្បាស់លាស់ត្រូវដោះស្រាយដោយផ្តល់ប្រយោជន៍ដល់ អោ អាន**

43. នៅក្នុងករណីដែលមិនមានភស្តុតាងពីការអនុវត្តរបស់រដ្ឋ ឬ*ទស្សនៈច្បាប់* ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលរួមទាំងយុទ្ធជនទៅក្នុងអត្ថន័យនៃ “ប្រជាជនស៊ីវិល” សហចៅក្រមស៊ើបអង្កេតអន្តរជាតិចាំបាច់ត្រូវដោះស្រាយភាពមិនច្បាស់លាស់នេះដោយផ្តល់ប្រយោជន៍ដល់ អោ អាន និងជនត្រូវចោទដទៃទៀតនៅក្នុងសំណុំរឿង ០០៣ និង០០៤។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវសម្រេចថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ “ប្រជាជនស៊ីវិល” មិនអាចរួមទាំងសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនរបស់រដ្ឋ ឬអង្គការឡើយ ដូច្នេះ ការវាយប្រហារទៅលើបុគ្គលទាំងអស់នេះ មិនអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[71]។

---

[70] *ឧទាហរណ៍, Blaškić*, កថាខណ្ឌ ១០៣ ដល់១១២។ Hansdeep Singh, “ការរិះគន់ចំពោះសាលក្រមអង្គជំនុំជម្រះសាលាដំបូង*(តុលាការICTY)” ក្នុងរឿងក្តី Mrkšić ៖ ការវាយតម្លៃឡើងវិញថាតើ ទាហានដែលបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ មានសិទ្ធិទទួលបានការទទួលស្គាល់ ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ,* ច្បាប់និងការអនុវត្តន៍របស់តុលាការអន្តរជាតិ 8 (2009) 247–296, ទំព័រ ២៨២ ដល់២៨៥, ភ្ជាប់ជាឧបសម្ព័ន្ធ ៤៣។

[71] *សូមមើល* លក្ខន្តិកៈទីក្រុងរ៉ូម, មាត្រា 22(2); *រដ្ឋអាជ្ញា តទល់នឹង Ngudjolo*, ICC, ICC-01/04-02/12, *“សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ”, ទស្សនៈយល់ស្របរបស់ចៅក្រម Christine Van den Wyngaert*, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១២, កថាខណ្ឌ ២០ ដល់២១, ភ្ជាប់ជាឧបសម្ព័ន្ធ ៤៤ (“បុគ្គលម្នាក់ៗចាំបាច់ត្រូវស្ថិតក្នុងស្ថានភាពមួយដែលដឹងឮនៅពេលចូលរួមក្នុងអំពើណាមួយថា ច្បាប់បានកំណត់អំពើនោះថាជាបទល្មើស... ទោះបីជានរណាម្នាក់ (ទាំងនៅក្នុង ឬនៅក្រៅ DRC)

## IV. **សេចក្តីសន្និដ្ឋាន**

44. មេធាវីការពារក្តី សូមលើកឡើងដោយសេចក្តីគោរពថា ការវាយប្រហារដោយរដ្ឋ ឬអង្គការ ទៅលើសមាជិកកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន មិនអាចចាត់ទុកថាជា ការវាយប្រហារទៅលើប្រជាជនស៊ីវិលបានឡើយ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ អត្ថន័យទូទៅនៃពាក្យ "ប្រជាជនស៊ីវិល" នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនរួមបញ្ចូលយុទ្ធជនឡើយ ដូច្នេះមិនមានការអនុវត្តរបស់រដ្ឋ ឬ*ទស្សនៈច្បាប់* តាំងពីមុនមក រួមទាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលផ្អែកលើមូលដ្ឋាននេះ ការវាយប្រហារទៅលើកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួនរបស់រដ្ឋ ឬអង្គការនោះ អាចចាត់ទុកថាជាការវាយប្រហារសំដៅលើប្រជាជនស៊ីវិលនោះ។ លើសពីនេះទៀត ប្រសិនបើសហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចស្វែងរកគោលការណ៍ណែនាំពីសេចក្តីសម្រេចដាច់ដោយឡែកមួយចំនួនតូចនោះ ដែលច្បាស់ណាស់ថាវាមិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ សេចក្តីសម្រេចទាំងនោះនឹងអនុញ្ញាតឱ្យតែការចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងនឹងជនរងគ្រោះជាយោធាដាច់ដោយឡែកមួយចំនួនតូចប៉ុណ្ណោះ នៅក្នុងការវាយប្រហារទៅលើប្រជាជនស៊ីវិល។ នេះមិនមែនជាស្ថានភាពដែលកំពុងចោទជាបញ្ហានេះឡើយ។ ជាចំណុចចុងក្រោយ ការដាក់បញ្ចូលការវាយប្រហារទៅលើកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន ដោយរដ្ឋ ឬអង្គការ ទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាអំពើខុសច្បាប់ ដែលរំលោភបំពានទាំងទៅលើគោលការណ៍នីត្យានុកូលភាព និងគោលការណ៍*វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ*។

សូមលោកសហចៅក្រមស៊ើបអង្កេតមេត្តាទទួលយកសារណានេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦

**សហមេធាវីការពារក្តីលោក អោ អាន**

| | | |
|---|---|---|
| មុំ លុជ្ស | Richard ROGERS | Göran SLUITER |

អាចបានដឹងមុនពេលអង្គបុរេជំនុំជម្រះបកស្រាយជាលើដំបូង នូវមាត្រា ២៥(៣)(ក) ដែលថាមាត្រានេះរួមមាននូវទម្រង់ល្អិតល្អន់ និងជាក់លាក់ នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ...")។